# ការសិក្សាប្រៀបធៀបលើការអនុវត្តការទូត ក្នុងការគ្រប់គ្រងទឹក ផ្ដោតលើទន្លេអ៊ីនឌុស និងទន្លេមេគង្គ

## សេចក្ដីផ្ដើម

ទឹកជាចំណែកដ៏ចាំបាច់មួយនៃជីវិត ក្នុងការជួយទ្រទ្រង់ជីវភាព វិបុលភាព និងស្ថិរភាពសង្គម ក្នុងទូទាំងពិភពលោក។ សារៈសំខាន់ចាំបាច់នៃទឹក ក៏មានចែងច្បាស់ក្នុងគោលដៅទី៦ ក្នុងចំណោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ទាំង៨ ដែលផ្ដោតលើការទទួលបានទឹកប្រើប្រាស់ប្រកបដោយសមធម៌ និងការគ្រប់គ្រងទឹកប្រកបដោយចីរភាព (SDG 2015-2030)។ ដើម្បីសម្រេចបាននូវគោលដៅទី៦ នៃ SDG នេះ ត្រូវមានសហប្រតិបត្តិការ លើបញ្ហាទឹកដែលឆ្លងកាត់ព្រំដែន ដូចមានចែងក្នុងអនុគោលដៅទី៦.៥។ ប៉ុន្តែ ដោយសារមានបញ្ហាប្រឈម ដូចជា កំណើនបញ្ហាកង្វះទឹក និងការគ្រប់គ្រងទឹកមិនបានត្រឹមត្រូវ ជម្លោះក្នុងបញ្ហាទឹកដែលឆ្លងកាត់ព្រំដែន អាចបង្កភាពរឹករវក្នុងសង្គម និងបង្កើតជាទំនាស់។ របាយការណ៍ស្ដីពីការអភិវឌ្ឍទឹកនៅអាស៊ីឆ្នាំ២០១៣ (Asian Water Development Outlook 2013) បានរកឃើញថា សន្តិសុខនៃការគ្រប់គ្រងទឹកក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក កំពុងប្រឈមនឹងការគំរាមកំហែងនៃជម្លោះស្ដីពីតម្រូវការធនធានទឹក សំពាធប្រជាសាស្ត្រ ឧស្សាហូបនីយកម្ម នគរូបនីយកម្ម និងការប្រែប្រួលអាកាសធាតុ ហើយទំនាស់ទាំងនេះ ទំនងអាចបង្កើនភាពតានតឹងដល់បណ្ដាប្រទេសនៅតាមដងទន្លេ (ADB 2013)។

អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក Kofi Annan បានលើកឡើងថា "ការប្រកួតប្រជែងដ៏តឹងតែងរវាងបណ្ដាប្រទេសលើបញ្ហាធនធានទឹក បង្កើតនូវការព្រួយបារម្ភពីលទ្ធភាពអាចមានជម្លោះឃោរឃៅ" (United Nations 2020)។ ទំនាស់ទាក់ទងនឹងធនធានទឹក បានក្លាយជាបញ្ហាដ៏ស្មុគស្មាញ ដែលអាចប៉ះពាល់ដល់សន្តិសុខអន្តរជាតិ ហើយដែលត្រូវបានដាក់ចូលក្នុងបញ្ជីហានិភ័យសកលកំពូលៗទាំងប្រាំ (World Economic Forum 2020)។ ការស្រាវជ្រាវបានបង្ហាញថា ជាទូទៅទំនាស់លើធនធានទឹក កើតឡើងនៅតាមបណ្ដាប្រទេសមានព្រំដែនទឹកជាមួយគ្នា (Molen and Hildering 2005; Petersen-Perlman, Veilleux and Wolf 2017; Gholizadeh and Niknami 2020)។ វិវាទទាំងនោះបានផ្ទុះឡើងនៅតាមដងទន្លេដូចជា៖ ទន្លេនីល អ៊ីនឌុស និង មេគង្គ ក៏ដូចជានៅតាមដងទន្លេជាច្រើនទៀត។ អត្ថបទនេះធ្វើការសិក្សា និងប្រៀបធៀប មូលហេតុដែលបង្កឲ្យមានទំនាស់លើធនធានទឹក និងពិនិត្យពីយន្តការប្រើប្រាស់ សម្រាប់ដោះស្រាយទំនាស់នៅអាងទន្លេអ៊ីនឌុស និងមេគង្គ។

## ទិដ្ឋភាពទូទៅនៃទន្លេអ៊ីនឌុស និងមេគង្គ

### *ទន្លេអ៊ីនឌុស*

ទន្លេអ៊ីនឌុស ដែលជួយទ្រទ្រង់ប្រជាជន ប្រមាណ ២១៥លាននាក់ ជាទន្លេវែងជាងគេលំដាប់ទី៨ ក្នុងពិភពលោក។ ទន្លេនេះមានប្រភពចេញពីភ្នំហិម៉ាល័យ ក្នុងតំបន់ខ្ពង់រាបទីបេខាងលិច ហើយមួយផ្នែកធំនៃទឹកទន្លេហូរកាត់តំបន់ Jammu និង Kashmir នៅភាគពាយព្យនៃអនុទ្វីបឥណ្ឌា។ ទន្លេអ៊ីនឌុស និងដៃទន្លេនានារបស់វា សំខាន់ជាខ្លាំងសម្រាប់ប្រទេសប៉ាគីស្ថាន និងឥណ្ឌា ព្រោះវាជាប្រភពទឹកដ៏ចម្បង សម្រាប់ផ្គត់ផ្គង់វិស័យកសិកម្មក្នុងប្រទេស។ ប៉ុន្តែដោយសារប្រជាជនប៉ាគីស្ថានប្រមាណជាង ៧០% ពឹងអាស្រ័យដោយផ្ទាល់ ឬដោយប្រយោលលើវិស័យកសិកម្ម ទន្លេអ៊ីនឌុស មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រជាជនប៉ាគីស្ថាន (Abbashi et al. 2019)។

ទំនាស់រវាងឥណ្ឌា នឹងប៉ាគីស្ថាន លើធនធានទឹកនៅអាងទន្លេអ៊ីនឌុស មិនមែនជាជម្លោះថ្មីនោះទេ ព្រោះវាបានចាប់ផ្ដើមតាំងពីឆ្នាំ១៩៤៧ ក្រោយពេលមានការបែងចែកអនុទ្វីបឥណ្ឌាជាប្រទេសឯករាជ្យពីរ គឺ ឥណ្ឌា និង ប៉ាគីស្ថាន ហើយបានតានតឹងកាន់តែខ្លាំងឡើងទៀត ចាប់តាំងពីពេលនោះមក។ ទំនាស់លើធនធានទឹកក្នុងអាងទន្លេអ៊ីនឌុស អាចបណ្ដាលមកពីកត្តាមួយចំនួន។ ទី១ គឺកត្តាជម្លោះទឹកដី ដែលកំពុងបន្តកើតមានក្នុងតំបន់ Kashmir

រូបភាព១៖ ផែនទីអាងទន្លេអ៊ីនឌុស




ប្រភព៖ Zawahri 2008

---

អត្ថបទនេះរៀបរៀងដោយ ផុន សុក្របញ្ញា, ជាទីប្រឹក្សា នៃវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង រស់ សយម្ភូ ជានិស្សិតបញ្ចប់ថ្នាក់អនុបណ្ឌិត ជំនាញច្បាប់អន្តរជាតិ នៃសាកលវិទ្យាល័យ Sussex និងជានិស្សិតថ្នាក់អនុបណ្ឌិត ជំនាញសន្តិសុខអន្តរជាតិ ទំនាស់ និងការអភិវឌ្ឍអន្តរជាតិ នៃសាកលវិទ្យាល័យ Leicester។ សូមយោងអត្ថបទនេះថា៖ Phon Sokpanya and Ros Sayumphu. 2020. “Comparative Study on the Implementation of Water Diplomacy: Focusing on the Indus and Mekong Rivers.” *Cambodia Development Review* 24 (3): 7–12.

ហើយបានធ្វើឲ្យទំនាក់ទំនងឥណ្ឌា-ប៉ាគីស្ថាន មានភាពល្អក់កករ និងបានបង្អាក់ សហប្រតិបត្តិការរវាងប្រទេសទាំងពីរ (Haq and Sofi 2019; Qureshi 2017a)។ ទី២ កំណើនបទឧក្រិដ្ឋភេរវកម្មនៅឥណ្ឌា បានធ្វើឲ្យទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ កាន់តែដុនដាបឡើង ជាពិសេសក្រោយពេលមានការវាយប្រហារនៅក្រុង Mumbai ក្នុងឆ្នាំ២០០៨ ដែលឥណ្ឌាបានចោទថា រដ្ឋាភិបាលប៉ាគីស្ថានជាអ្នកនៅពីក្រោយអំពើភេរវកម្ម ហើយប៉ាគីស្ថាន បានបដិសេធទាំងស្រុងនូវការចោទប្រកាន់នេះ (Parashar 2020)។ ទី៣ មូលហេតុដែលទំនងជាមានសំពាធខ្លាំងនោះ គឺការអះអាងរបស់ប៉ាគីស្ថានថា ឥណ្ឌាដែលនៅខ្សែទឹកខាងលើ គិតតែពីផលប្រយោជន៍របស់ខ្លួន ដោយបានគ្រួតត្រាលំហូរទឹកទន្លេ និងធ្វើឲ្យរាំងស្ទះដល់ចង្វាក់ផលិតកម្មកសិកម្ម និងប៉ះពាល់ដល់ការរស់នៅ និងជីវភាពរបស់ប្រជាជនប៉ាគីស្ថាន។

### ទន្លេមេគង្គ

ទន្លេមេគង្គ ជាទន្លេវែងជាងគេលំដាប់ទី១២ ក្នុងពិភពលោក។ ទន្លេនេះហូរចេញពីខ្ពង់រាបទីបេ រហូតដល់ដីសណ្តទន្លេមេគង្គ ដោយឆ្លងកាត់ ៦ប្រទេសគឺ ចិន មីយ៉ាន់ម៉ា ឡាវ ថៃ កម្ពុជា និងវៀតណាម។ អាងទន្លេមេគង្គស្ថិតក្នុងចំណោមអាងធំជាងគេ និងមានជីវចម្រុះច្រើនជាងគេនៅអាស៊ីអាគ្នេយ៍ ដែលបានផ្តល់ជាប្រភពជួយចិញ្ចឹមជីវិតប្រជាជនប្រមាណជាង ៦០លាននាក់។ ក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះ បណ្តាប្រទេសតាមដងទន្លេបានទាញយកអត្ថប្រយោជន៍ពីទន្លេមេគង្គ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហូបនីយកម្ម ហើយប្រទេសទាំងនោះក៏អាចធ្វើការអភិវឌ្ឍស្ទុះតាមបណ្តាប្រទេសជឿនលឿន កាត់បន្ថយភាពក្រីក្រ និងពង្រីកសមាហរណកម្មក្នុងតំបន់។

រូបភាព២៖ ផែនទីអាងទន្លេមេគង្គ




ប្រភព៖ ក្រសួងធនធានធម្មជាតិ និងបរិស្ថាន 2015
www.mekongeye.com/ wp-content/uploads/sites/2/2016/04/MDS-Final-Project-Report-Eng.pdf

ការប៉ះទង្គិចដែលបានផ្ទុះឡើងជុំវិញទន្លេមេគង្គ មានច្រើនសណ្ឋាន ហើយចំណុចលេចធ្លោជាងគេគឺ វត្តមានការចូលរួមពីបណ្តាប្រទេសដែលមិនស្ថិតនៅក្នុងអនុតំបន់ទន្លេមេគង្គ ក្នុងការដោះស្រាយការទូតលើការគ្រប់គ្រងទឹក។ ការប្រជែងគ្នាផ្នែកភូមិសាស្ត្រនយោបាយ និងការប្រទាញប្រទង់គ្នារវាងមហាអំណាចជាពិសេស ការលូកដៃចូលរបស់សហរដ្ឋអាមេរិកក្នុងបញ្ហាទន្លេមេគង្គ ត្រូវបានចាត់ទុកថាជាមូលហេតុដ៏ចម្បងមួយនៃទំនាស់ (Chang 2013)។ ក្នុងដំណើរការនៃការប្រកួតប្រជែងនេះ ក៏មានគំនិតផ្តួចផ្តើម ធ្វើសហប្រតិបត្តិការជាច្រើនរបស់ប្រទេសចិន (សហប្រតិបត្តិការមេគង្គ-ឡានឆាង) សហរដ្ឋអាមេរិក (ភាពជាដៃគូសហរដ្ឋអាមេរិក-មេគង្គ ដែលត្រូវបានពង្រឹង និងប្តូរឈ្មោះពី គំនិតផ្តួចផ្តើមតំបន់ទន្លេមេគង្គក្រោម) ជប៉ុន (មេគង្គ-ជប៉ុន) និងកូរ៉េខាងត្បូង (មេគង្គ-កូរ៉េខាងត្បូង) និងគំនិតផ្តួចផ្តើមបង្កើតដោយស្ថាប័នក្នុងតំបន់ និងអន្តរជាតិជាច្រើនទៀត។

ថ្វីបើប្រទេសតាមដងទន្លេមេគង្គ ជាពិសេសបណ្តាប្រទេសនៅខ្សែទឹកខាងក្រោម បានទទួលអត្ថប្រយោជន៍គួរឲ្យកត់សម្គាល់ជាច្រើនពី គំនិតផ្តួចផ្តើមសហប្រតិបត្តិការនានា ជាពិសេសតាមរយៈសកម្មភាពនៃគម្រោងផ្សេងៗក្តី ប៉ុន្តែក្នុងនេះ តំបន់ទន្លេមេគង្គ បានក្លាយជាសមរភូមិយុទ្ធសាស្ត្រមួយនៃពួកមហាអំណាច (Hirsch 2016)។ បន្ថែមលើនេះទៀត ការរិះគន់ឥតឈប់ឈរលើការសាងសង់ទំនប់ទឹកជាឯកច្ឆន្ទរបស់ចិន ដោយគ្មានការពិភាក្សាច្បាស់លាស់ជាមួយ បណ្តាប្រទេសនៅខ្សែទឹកខាងក្រោម បានធ្វើឲ្យជម្លោះកាន់តែតានតឹងឡើង និងបានបង្ហាញច្បាស់ពីទំនាក់ទំនង និងសិទ្ធិអំណាចមិនស្មើភាព និងធ្វើឲ្យមានការមិនទុកចិត្តគ្នាទៅវិញទៅមក រវាងបណ្តាប្រទេសនៅក្នុងតំបន់ (Chang 2013)។

### ក្របខ័ណ្ឌការទូតក្នុងការគ្រប់គ្រងទឹក ដើម្បីដោះស្រាយវិវាទទឹក

ទោះបីជាជម្លោះលើធនធានទឹក បានតានតឹងឡើងទៀត ប៉ុន្តែវិវាទនេះគួរតែអាចដោះស្រាយបានប្រកបដោយប្រសិទ្ធភាព និងចីរភាព ដើម្បី

ជំរុញសមាហរណកម្ម និងសហប្រតិបត្តិការក្នុងតំបន់ និងសម្រេចបានវិបុលភាព និងការអភិវឌ្ឍទាំងអស់គ្នា។ ការទូតក្នុងការគ្រប់គ្រងទឹក ជាការទូតថ្មីមួយ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយទំនាស់ទឹកឆ្លងកាត់ព្រំដែន និងជាវិធីសាស្ត្រយុទ្ធសាស្ត្រមួយដែលមានការចូលរួម និងពិភាក្សាគ្នាពីសំណាក់អ្នកពាក់ព័ន្ធនិងអ្នកនយោបាយនានា ក្នុងគោលបំណងពង្រឹងសន្តិភាព ស្ថិរភាព និងការរីកចម្រើន (Hefny 2011; Molnar et al. 2017)។ យោងតាម Hefny (2011) និង Molnar et al. (2017) ការសិក្សានេះបានកំណត់និយមន័យ ការទូតក្នុងការគ្រប់គ្រងទឹកថាជា ការព្យាយាមដោះស្រាយនិងកាត់បន្ថយទំនាស់លើធនធានទឹក កសាងទំនុកចិត្ត លើកកម្ពស់សហប្រតិបត្តិការ និងពង្រឹង សមាហរណកម្មក្នុងតំបន់ សន្តិភាព និងសុវត្ថិភាព តាមរយៈការប្រើប្រាស់បញ្ចូលគ្នានូវវិធីសាស្ត្រច្រើនយ៉ាង ដូចជា មជ្ឈត្តកម្ម ចំណេះដឹងផ្នែកច្បាប់ និងចំណេះដឹងបានពីការសិក្សារកឃើញជាក់ស្តែង។ ផ្អែកពីរដូចតទៅនេះ មានពន្យល់ពីយន្តការ និងក្របខ័ណ្ឌផ្សេងៗ ដែលត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយទំនាស់នានានៅអាងទន្លេអ៊ីនឌុស និងមេគង្គ។

### *អាងទន្លេអ៊ីនឌុស*

វិវាទទឹកនៅអាងទន្លេអ៊ីនឌុស បានចាប់ផ្តើមវិវត្តធ្ងន់ធ្ងរក្រោយពេលប្រទេសឥណ្ឌាទទួលបានឯករាជ្យនៅឆ្នាំ១៩៤៧។ បន្ទាប់ពីមានការចរចាដឹកនាំដោយធនាគារពិភពលោក អស់រយៈពេលជិតមួយទសវត្សរ៍មក សន្ធិសញ្ញាទឹកអ៊ីនឌុស (IWT) ក៏ត្រូវបានអនុម័តក្នុងឆ្នាំ១៩៦០ ដើម្បីដោះស្រាយ និងកាត់បន្ថយជម្លោះរវាងភាគីទាំងពីរ (Alam 2002)។ IWT បានចែងថា ទន្លេអ៊ីនឌុសត្រូវបានខណ្ឌចែកគ្នាជាពីរដោយ ដែទន្លេនៅភាគខាងកើតត្រូវប្រគល់ឲ្យឥណ្ឌា និងដែទន្លេនៅភាគខាងលិច ឲ្យទៅប៉ាគីស្ថាន (Sarfraz 2013)។ ក្នុងនោះផងដែរ IWT តម្រូវឲ្យប្រទេសទាំងពីរ៖ (១) មិនបង្អាក់លំហូរទឹក ឬបង្កគ្រោះថ្នាក់ដល់ភាគីម្ខាងទៀត និង (២) ធ្វើសហប្រតិបត្តិការជាមួយគ្នា និងផ្តល់ឲ្យគ្នាទៅវិញទៅមកនូវទិន្នន័យធារាសាស្ត្រ (Sarfraz 2013)។

បទបញ្ញត្តិទាំងឡាយនៅក្នុង IWT បន្តអនុវត្តបានជាង ៥០ឆ្នាំមកហើយ ទោះបីក្នុងអំឡុងពេលឥណ្ឌា-ប៉ាគីស្ថានមានសង្គ្រាមរវាងគ្នាក្នុងឆ្នាំ១៩៦៥ ១៩៧១ និង ១៩៩៩ (Ranjan 2016) ក្តី។ ប្រហែលមានកត្តាពីរយ៉ាងដែលធ្វើឲ្យ IWT ត្រូវបានចាត់ទុកជាសន្ធិសញ្ញាមួយមានជោគជ័យជាងគេ ក្នុងការដោះស្រាយវិវាទទឹក។ ទី១ ជោគជ័យដ៏ធំធេងនេះ បានមកពីឆន្ទៈរបស់ឥណ្ឌា និងប៉ាគីស្ថាន ក្នុងការដោះស្រាយជម្លោះទឹកនេះ ដោយចាត់ទុកថាវាជាបញ្ហាបច្ចេកទេស ជាជាងគិតថាវាជាបញ្ហាភូមិសាស្ត្រនយោបាយ។ ជាការឆ្លើយតប ប្រទេសទាំងពីរបានព្រមព្រៀងគ្នាបង្កើត គណៈកម្មការអចិន្ត្រៃយ៍ទន្លេអ៊ីនឌុស (PIC) ដែលមានសមាសភាពវិស្វករបច្ចេកទេសជាន់ខ្ពស់ពីរនាក់ គឺម្នាក់ត្រូវបានតែងតាំងដោយឥណ្ឌា និងម្នាក់ទៀតដោយប៉ាគីស្ថាន។ គោលគំនិតនៃការបង្កើតក្រុមការងារនេះ គឺដើម្បីឲ្យប្រទេសទាំងពីរអាចអភិវឌ្ឍនិងគ្រប់គ្រងទន្លេអ៊ីនឌុសរួមគ្នា អនុលោមតាមបទបញ្ញត្តិរបស់ IWT។ ទី២ ក្នុងករណីដែល PIC មិនអាចចេញសេចក្តីសម្រេចណាមួយ ដែលភាគីទាំងសងខាងអាចទទួលយកបាន ឬមិនអាចដោះស្រាយទំនាស់ទឹករវាងប្រទេសទាំងពីរបាននោះ ភាគីទាំងពីរត្រូវរកភាគីទី៣ ដែលជាអ្នកជំនាញមកជួយសម្រុះសម្រួល ឬក៏ប្តឹងទៅតុលាការមជ្ឈត្តកម្មអចិន្ត្រៃយ៍ (PCA) ដើម្បីដោះស្រាយទំនាស់។

ប៉ុន្តែដោយឡែក ទោះបីជាមានការបង្កើត IWT និង PIC សម្រាប់គ្រប់គ្រងទន្លេអ៊ីនឌុសក្តី ឥណ្ឌានៅតែបន្តសាងសង់ទំនប់ទឹកតាមដងទន្លេជាច្រើន ដែលធ្វើឲ្យប៉ាគីស្ថានមានការខឹងសម្បា និងធ្វើឲ្យមានការប៉ះទង្គិចគ្នាជាច្រើនលើក (Qureshi 2017b)។ ទោះបីជា PIC បានដោះស្រាយបញ្ហាជាច្រើនរវាងប៉ាគីស្ថាន និងឥណ្ឌាក្តី ក៏នៅមានបញ្ហាពីរដែល PIC មិនអាចដោះស្រាយបានពោលគឺ ក្តីបារម្ភរបស់ប៉ាគីស្ថានលើទំនប់ទឹក Baglihar និង Kishenganga របស់ឥណ្ឌា (Sarfraz 2013)។ ដូច្នេះ តាមលក្ខខណ្ឌដែលមានចែងក្នុង IWT ទំនប់ទឹកទាំងពីរត្រូវមានការដាក់ឲ្យធ្វើការសិក្សាស្រាវជ្រាវដោយ អ្នកជំនាញឯករាជ្យម្នាក់ដែលចាត់តាំងឡើងដោយធនាគារពិភពលោក និងការដោះស្រាយតាមរយៈយន្តការតុលាការ PCA (Rao 2017)។ ទាក់ទិននឹងទំនាស់លើទំនប់ Baglihar នេះ ប៉ាគីស្ថានបានជំទាស់នឹងការសាងសង់ទំនប់ ដោយសារវាមានហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ តែខាងឥណ្ឌាបានលើកថា ទំនប់នេះមិនប៉ះពាល់ដល់លំហូរទឹកទេ។ ដោយសារតែភាពមិនចុះសម្រុងគ្នានេះ អ្នកជំនាញឯករាជ្យម្នាក់ត្រូវបានចាត់តាំងឲ្យមកវាយតម្លៃស្ថានភាពជាក់ស្តែង ហើយក៏បានចេញសេចក្តីសម្រេចថា គម្រោងនេះមិនបង្កផលប៉ះពាល់អាក្រក់ទេ ប៉ុន្តែត្រូវមានការកែតម្រូវបន្តិចបន្តួចក្នុងការសាងសង់ទំនប់នេះ។ ក្នុងករណីទី២ ក្តីបារម្ភរបស់ប៉ាគីស្ថានផ្តោតលើការរាំងស្ទះលំហូរទឹកទន្លេ និងការថយចុះកម្រិតទឹកក្នុងអាងទន្លេដែលបណ្តាលមកពីការសង់ទំនប់ទឹក Kishengang។ ប៉ាគីស្ថានបានប្តឹងទៅ PCA ហើយសាលក្រមចុងក្រោយរបស់តុលាការបានកំណត់ថា រដ្ឋនានាអាចសាងសង់ទំនប់បាន ប៉ុន្តែឥណ្ឌាត្រូវមានទំនួលខុសត្រូវ ក្នុងការធានាឲ្យមានលំហូរទឹកកម្រិតអប្បបរមាដើម្បីទប់ស្កាត់ការថយចុះកម្រិតទឹកក្នុងអាង (លើកលែងតែក្នុងស្ថានភាពចាំបាច់បន្ទាន់) និងក្នុងការការពារបរិស្ថានតាមដងទន្លេ (Sidhu 2013; Rao 2017)។

ក្នុងប្រាំទសវត្សរ៍កន្លងមកនេះ PIC ដំណើរការបានល្អរហូតមក ទោះបីជាមានទំនាស់ទឹកដី និងការប្រទូសរ៉ាយគ្នារវាងប្រទេសទាំងពីរក្តី (Sinha, Gupta and Behuria 2012)។ សមិទ្ធផលដ៏គួរឲ្យកត់សម្គាល់នេះ បានមកពីតម្លាភាព និងភាពមិនលំអៀងរបស់ PIC ក្នុងការអនុវត្តតួនាទីរបស់ខ្លួន (Zawahri 2008)។ ម្យ៉ាងទៀតបទបញ្ញតិក្នុង IWT បានកំណត់ឲ្យ PIC ធ្វើទស្សនកិច្ចជាផ្លូវការ ត្រួតពិនិត្យដងទន្លេអ៊ីនឌុសរៀងរាល់ប្រាំឆ្នាំម្តង ក្រៅពីការប្រជុំប្រចាំឆ្នាំរបស់ PIC និងការប្រជុំជាពិសេសផ្សេងៗទៀតដែលកើតឡើងតាមការស្នើរបស់សមាជិកគណៈកម្មការ នៃភាគីនីមួយៗ (Zawahri 2008)។ មួយវិញទៀត ក្រៅតែពីធនាគារអន្តរជាតិសម្រាប់ការសាងសង់ឡើងវិញ និងអភិវឌ្ឍន៍ (IBRD ដែលគេតែងហៅថា ធនាគារពិភពលោក) IWT មិនអនុញ្ញាតឲ្យមានការចូលរួមពីស្ថាប័នសាធារណៈ ឬអន្តរជាតិណាឡើយ (Khan 1990)។ ការប្រតិបត្តិយ៉ាងតឹងរ៉ឹងតាមបទបញ្ញត្តិទាំងនេះ

បានធ្វើឲ្យទំនាស់ក្នុងអាងទន្លេអ៊ីនឌុស រវាងប្រទេសទាំងពីរ អាចដោះស្រាយបានដោយសន្តិភាព ដោយប្រើមធ្យោបាយការទូតជាពិសេស ការចរចា ការពិគ្រោះយោបល់ និងការផ្សះផ្សារ ដោយ PIC និងការសម្រុះសម្រួលដោយធនាគារពិភពលោក និងការសម្រេចសេចក្ដីដោយ PCA ។

## ***ទន្លេមេគង្គ***

ទន្លេមេគង្គ ក៏ជាប្រភពសំខាន់មួយនៃ ជម្លោះលើធនធានទឹកដែរ។ បើពិនិត្យពីប្រវត្តិនៃសហប្រតិបត្តិការរវាងប្រទេសតាមដងទន្លេមេគង្គក្រោម (កម្ពុជា ឡាវ ថៃ និង វៀតណាម) ទំនាស់បានផ្ទុះឡើងជាលើកដំបូង ក្រោយពេលបង្កើតគណៈកម្មការមេគង្គ ក្នុងឆ្នាំ១៩៥៧។ ដោយសារសង្គ្រាមមនោគមន៍វិជ្ជាក្នុងតំបន់ និងសង្គ្រាមស៊ីវិលនៅកម្ពុជា សហប្រតិបត្តិការដែលគណៈកម្មការមេគង្គបានបង្កើតឡើង គឺមិនបានដំណើរការដោយរលូនទេ (Sunchindah 2005)។ នៅឆ្នាំ១៩៩៥ ដោយសារមានការគាំទ្រពីអង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិនានា គណៈកម្មការមេគង្គ ត្រូវបានកែប្រែឈ្មោះជា គណៈកម្មការទន្លេមេគង្គ (MRC) ដោយមានគណៈកម្មការមេគង្គតំណាងឲ្យបណ្ដាប្រទេសក្នុងអនុតំបន់ទន្លេមេគង្គជាសមាជិក ប៉ុន្តែប្រទេស ចិន និងមីយ៉ាន់ម៉ា មិនបានចូលជាសមាជិកទេ គឺបានធ្វើជាដៃគូសន្ទនា។ នាពេលបច្ចុប្បន្ន អាណត្តិរបស់ MRC រួមមាន ការត្រួតពិនិត្យអនុវត្តគោលនយោបាយផ្សេងៗ សម្របសម្រួលផែនការរបស់បណ្ដាប្រទេសសមាជិក សំដៅឲ្យមានការអភិវឌ្ឍប្រកបដោយសមភាពនិងសមធម៌សម្រាប់សង្គម ការពារបរិស្ថាន និងរក្សាភាពគង់វង្សនៃប្រព័ន្ធអេកូឡូស៊ី រួមទាំងសិក្សាលើការអភិវឌ្ឍលើទន្លេមេគង្គ និងដៃទន្លេប្រកបដោយចីរភាព ហើយក្នុងនោះក៏មានរួមបញ្ចូលការសាងសង់ទំនប់ទឹកផងដែរ (Gerlak and Haefner 2017)។ នៅឆ្នាំ២០០៣ ភាគីទាំងអស់បានបង្កើតកិច្ចព្រមព្រៀងទន្លេមេគង្គ ដែលបានដាក់ចេញនូវ នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀងគ្នា (PNPCA)[១] ក្នុងការគ្រប់គ្រងទន្លេ។

នាពេលកន្លងមក MRC ធ្លាប់បានសម្រុះសម្រួលវិវាទជាច្រើនរវាងរដ្ឋជាសមាជិក។ ក្នុងករណីពុំមានដំណោះស្រាយ គឺត្រូវបង្វែរយន្តការមកធ្វើការចរចាគ្នារវាងរដ្ឋពាក់ព័ន្ធ ដោយអនុលោមតាមកិច្ចព្រមព្រៀងទន្លេមេគង្គ។ ខុសប្លែកពីលក្ខខណ្ឌក្នុង IWT កិច្ចព្រមព្រៀងទន្លេមេគង្គ មិនមានគូសបញ្ជាក់ពីលក្ខខណ្ឌធ្វើមជ្ឈត្តកម្មឡើយ។

MRC ក៏ត្រូវបានប្រើប្រាស់ជាវេទិកាការទូតក្នុងការគ្រប់គ្រងទឹកដែលសំដៅដល់ ការជួយសម្រួលការចរចាលើបញ្ហាទឹកក្នុងតំបន់។ ករណីជាក់ស្ដែងមួយគឺ ការសាងសង់ទំនប់ជាច្រើនរបស់ប្រទេសចិននៅលើលំហូរធំនៃទន្លេមេគង្គ ក្នុងអាងទន្លេខាងលើ។ ដើម្បីធានាឲ្យមានតម្លាភាពទិន្នន័យធារាសាស្ត្រ ផ្ដល់ជាភស្តុតាងបញ្ជាក់ និងធ្វើឲ្យបណ្ដាប្រទេសនៅខ្សែទឹកខាងក្រោម មានទំនុកចិត្ត MRC បានប្រមូលទិន្នន័យធារាសាស្ត្រពីតំបន់នានា នៅទន្លេខាងលើ សម្រាប់ប្រើក្នុងការវិភាគជាលក្ខណៈបច្ចេកទេសវិទ្យាសាស្ត្រ និងតាក់តែងច្បាប់គ្រប់គ្រងទឹក ដើម្បីចែករំលែកជាមួយរដ្ឋជាសមាជិក ដៃគូអភិវឌ្ឍន៍អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល (NGOs) នានា (Schmeier 2011)។

ក្នុងពេលថ្មីៗនេះដែរ ចិនបានចុះកិច្ចព្រមព្រៀង ចែករំលែកទិន្នន័យធារាសាស្ត្រពេញមួយឆ្នាំ ជាមួយបណ្ដាប្រទេសក្នុងអនុតំបន់ទន្លេមេគង្គ (MRC 2020)។ គួររំលឹកផងដែរថា មុនពេលចុះកិច្ចព្រមព្រៀងនេះ ចិនយល់ព្រមផ្ដល់ឲ្យ MRC តែទិន្នន័យធារាសាស្ត្រ និងកម្រិតទឹកភ្លៀង ដែលមានរយៈពេលតែប្រាំខែក្នុងរដូវវស្សា (ពីខែមិថុនា ដល់ តុលា) ប៉ុណ្ណោះ។ បន្ថែមលើនេះ ដើម្បីបង្ហាញនូវសហប្រតិបត្តិការកាន់តែស្អិតរមួត និងការយកចិត្តទុកដាក់លើមហាអនុតំបន់មេគង្គ ចិនបានដាក់ចេញនូវសហប្រតិបត្តិការមេគង្គ-ឡានឆាង នៅឆ្នាំ២០១៥ ដែលរួមមានការធ្វើសហការ និងផ្ដល់ជាគម្រោងអភិវឌ្ឍន៍ដល់ប្រទេសទាំងអស់នៅតាមដងទន្លេ ក្នុងមហាអនុតំបន់មេគង្គ (Biba 2018)។

ទោះបីតាមការមើលពីខាងក្រៅ MRC មានសារៈសំខាន់ក្ដី ប៉ុន្តែគណៈកម្មការនេះ ហាក់ដូចជាមានសិទ្ធិអំណាច និងមានជោគជ័យតិចតួចក្នុងការដោះស្រាយវិវាទ (Kittikhoun and Staubi 2018)។ មូលហេតុទំនងជាអាចមកពីភាពខុសគ្នានៃការទាញយកប្រយោជន៍ពី ការប្រើប្រាស់ទឹកទន្លេមេគង្គរបស់រដ្ឋជាសមាជិកនីមួយៗ និងការគិតគូរតែពីផលប្រយោជន៍ជាតិខ្លួនតែប៉ុណ្ណោះ (Gerlak and Haefner 2017; Sok 2020)។ ជាឧទាហរណ៍ ករណីទំនប់ Xayaburi និង Don Sahong ដែលឡាវបានស្នើឡើងក្នុងឆ្នាំ២០១០ និង ២០១៤ MRC មិនមានសមត្ថភាពបញ្ចុះបញ្ចូលឲ្យរដ្ឋសមាជិកអនុវត្តតាម PNPCA បានទេ ដូច្នេះហើយ ការសាងសង់ទំនប់ក៏ត្រូវបានពន្យាពេល (Gerlak and Haefner 2017)។ ម្យ៉ាងទៀត កង្វះឆន្ទៈ និងការប្ដេជ្ញាចិត្តផ្នែកនយោបាយ របស់ប្រទេសជាសមាជិកមួយចំនួន បានធ្វើឲ្យ MRC មិនមានលទ្ធភាពបន្តអនុវត្តបាននូវការទូតក្នុងការគ្រប់គ្រងទឹក រួមទាំងក្របខ័ណ្ឌច្បាប់ផ្សេងៗទៀត។ ដោយសារមានទំនាស់ផលប្រយោជន៍ ក្នុងចំណោមអ្នកដឹកនាំនយោបាយនេះហើយ ថៃ ជាឧទាហរណ៍ មិនបានបោះឆ្នោតយល់ព្រមលើកិច្ចព្រមព្រៀង វាយតម្លៃផលប៉ះពាល់បរិស្ថានឆ្លងកាត់ព្រំដែន ការចែករំលែកទឹក និងគុណភាពទឹក ដែល MRC បានស្នើឡើង (Campbell 2011) នោះទេ។ ដោយសារកិច្ចព្រមព្រៀងនេះ ត្រូវមានលទ្ធផលបោះឆ្នោតជាឯកច្ឆន្ទ កិច្ចព្រមព្រៀងនេះ គឺមិនអាចសម្រេចបានទេ។

## **សេចក្ដីសន្និដ្ឋាន**

ទឹកជាតម្រូវការចាំបាច់សម្រាប់ការរស់រានមានជីវិត។ ប៉ុន្តែដោយសារ កំណើនតម្រូវការធនធានទឹក ការគ្រប់គ្រងទឹកមិនត្រឹមត្រូវ ភាពមិនទុកចិត្តគ្នា ការប្រែប្រួលអាកាសធាតុ និងជាពិសេស ការចូលរួមប្រកួតប្រជែងអំពីសំណាក់មហាអំណាចធំៗ ទឹកបានក្លាយជាប្រភពនៃទំនាស់ទៅវិញ។ ភាគច្រើននៃជម្លោះទឹកកើតឡើងនៅតាមប្រទេសដែលមានព្រំដែនទឹករួមគ្នារវាង ពីរ ឬ

[១] PNPCA ជាគោលការណ៍ទូទៅរួមមួយ ដែលត្រូវបានរៀបចំដោយគណៈកម្មការក្នុងការធានាឲ្យមានលំហូរ និងគុណភាពទឹកសម្រាប់អាងទន្លេ ដោយផ្ដោតលើគម្រោងនានា រួមមាន វារីអគ្គិសនី ប្រព័ន្ធធារាសាស្ត្រខ្នាតធំ និងគម្រោងជាច្រើនផ្សេងទៀត។

ច្រើនប្រទេស។ ដូចការសិក្សាបានបង្ហាញនៅខាងលើ ទំនាស់លើធនធានទឹកអាចទប់ស្កាត់ ឬកាត់បន្ថយបាន តាមរយៈការអនុវត្តការទូតក្នុងការគ្រប់គ្រងទឹក។

ការលើកកម្ពស់ក្របខ័ណ្ឌច្បាប់ផ្សេងៗក្នុងតំបន់ អាចជួយឲ្យមានដំណោះស្រាយប្រកបដោយសន្តិវិធី លើជម្លោះទឹករវាងរដ្ឋនានានៅតាមដងទន្លេ។ ការបង្កើតអង្គភាព ឬគណៈកម្មការត្រួតពិនិត្យ ដែលដើរតួនាទីជាអ្នកសម្របសម្រួល ឃ្លាំមើល និងដោះស្រាយទំនាស់ផ្សេងៗ ដោយផ្តល់ភស្តុតាងបែបវិទ្យាសាស្ត្រកសាងទំនុកចិត្ត និងជំរុញសហប្រតិបត្តិការ គឺសុទ្ធតែជាលក្ខខណ្ឌចាំបាច់។ ដូចបានលើកឡើងរួចមកហើយ ការសម្រុះសម្រួល និងដោះស្រាយវិវាទទឹកនៅអាងទន្លេអ៊ីនឌុស និងមេគង្គ វាអាស្រ័យលើការប្រើប្រាស់ការទូតក្នុងការគ្រប់គ្រងទឹក តាមរយៈ PIC និង MRC នៃកិច្ចព្រមព្រៀងលើទន្លេទាំងពីរ។ ជារួម PIC មើលទៅទំនងមានជោគជ័យជាង ក្នុងការដោះស្រាយបញ្ហាទឹកដោយសន្តិវិធីនៅអាងទន្លេអ៊ីនឌុស ហើយ MRC ហាក់ដូចមានសិទ្ធិអំណាច និងជោគជ័យតិចតួច ក្នុងការដោះស្រាយទំនាស់ធនធានទឹក។ ដោយផ្អែកលើករណីសិក្សាទាំងពីរ ការសិក្សានេះបានលើកជាមតិដូចតទៅ៖

១. ជាការសំខាន់ដែលបណ្តារដ្ឋនៅតាមដងទន្លេ ត្រូវកសាងទំនុកចិត្តរវាងគ្នាទៅវិញទៅមក និងពង្រឹងការប្តេជ្ញាចិត្តផ្នែកនយោបាយ ដើម្បីសម្រេចបានការអភិវឌ្ឍទាំងអស់គ្នា (synergies) សម្របសម្រួលគោលនយោបាយ និងពង្រីកសហប្រតិបត្តិការឲ្យបានល្អបំផុត ក្នុងការប្រើប្រាស់ប្រភពទឹករួមគ្នា និងទទួលបានផលប្រយោជន៍ពីធនធានទឹកទាំងអស់គ្នា។ ក្នុងនោះដែរ ការប្រើប្រាស់ទឹកដោយសមរម្យនិងស្មើភាពគ្នាដូចមានចែងក្នុងច្បាប់អន្តរជាតិ និងកិច្ចព្រមព្រៀងនៅក្នុងតំបន់ គឺមិនត្រូវរំលោភបំពានឡើយ។

២. ការទាញយកបទពិសោធន៍ពី ការដោះស្រាយទំនាស់ដោយជោគជ័យតាម IWT ដែលអនុវត្តបានយូរឆ្នាំមកហើយនេះ បញ្ហាប្រឈមផ្សេងៗនៃទន្លេមេគង្គ គឺអាចកាត់បន្ថយ និងគ្រប់គ្រងបានកាន់តែល្អ បើសិនមិនមានការចូលរួមច្រើនពីតួអង្គខាងក្រៅ និងការឈប់ដាក់របៀបវារៈយោធា នៅក្នុងតំបន់ទន្លេមេគង្គ។ "ការនឿយណាយនឹងគំនិតផ្តួចផ្តើមទន្លេមេគង្គដ៏ច្រើនសម្បើម (Mekong Initiative Fatigue)" ដោយសារមានគំនិតផ្តួចផ្តើមច្រើនពេក ដែលដឹកនាំដោយតួអង្គជារដ្ឋផ្សេងៗជាច្រើន ជាពិសេសគំនិតផ្តួចផ្តើមផ្តោតលើវេទិកាសន្ទនា ជាជាងលើគម្រោងអភិវឌ្ឍ បានធ្វើឲ្យបញ្ហាទន្លេមេគង្គកាន់តែស្មុគស្មាញ និងបញ្ឆេះការប្រជែងគ្នាផ្នែកនយោបាយ។ ផលប្រយោជន៍អាចទទួលបានច្រើនជាងសម្រាប់បណ្តាប្រទេសនៅតំបន់មេគង្គក្រោម បើសិនគំនិតផ្តួចផ្តើមទាំងនោះ ផ្តោតជាសំខាន់លើសហប្រតិបត្តិការទៅវិញទៅមក និងការអភិវឌ្ឍ។

៣. បណ្តាប្រទេសជាសមាជិក MRC គួរពង្រឹង និងពង្រីកសហប្រតិបត្តិការជាមួយប្រទេសជិតខាង នៅទន្លេមេគង្គខាងលើ រួមមាន ចិន និង មីយ៉ាន់ម៉ា ជាពិសេសលើបញ្ហាគ្រប់គ្រងភាពរាំងស្ងួត និងការប្រែប្រួលអាកាសធាតុ។ ចិន និង មីយ៉ាន់ម៉ា បានក្លាយជាដៃគូសន្ទនាតាំងពីឆ្នាំ១៩៩៦ មក ប៉ុន្តែរហូតមកដល់ពេលថ្មីៗនេះ ការយកចិត្តទុកដាក់នៅមានតិចតួច និងមានកម្រិត ក្នុងការចូលរួមជាមួយ MRC ដែលជាយន្តការសម្រាប់ជំរុញសហប្រតិបត្តិការ។ ដូចនេះ បើសិនប្រទេសទាំងប្រាំមួយ (គឺមានទាំង ចិន និង មីយ៉ាន់ម៉ា ផង) ក្លាយជាសមាជិកក្នុងវេទិកា MRC តែមួយនោះ ការធ្វើសហប្រតិបត្តិការ គឺរឹតតែមានប្រសិទ្ធភាពខ្ពស់។

៤. បណ្តាប្រទេសនៅតំបន់មេគង្គ គួរព្រមព្រៀងគ្នាចាត់ទុកវិវាទទឹកជាបញ្ហាបច្ចេកទេស ដូចក្នុងករណី IWT ជាជាងគិតថាវាជាបញ្ហាភូមិសាស្ត្រនយោបាយ។ ប្រទេសទាំងនេះ ក៏គួរជៀសវាងទំនោរនាំយកប្រទេសមហាអំណាច មកប្រជែងគ្នានៅក្នុងវិវាទទឹក ពីព្រោះធ្វើដូច្នេះអាចនាំឲ្យមានការដាក់របៀបវារៈ សន្តិសុខ និងយោធានៅក្នុងតំបន់មេគង្គ ដែលអាចបញ្ឆេះទំនាស់ធ្វើឲ្យបញ្ហាទឹកកាន់តែស្មុគស្មាញថែមទៀត។

## សេចក្តីថ្លែងអំណរគុណ

ការសិក្សានេះ ជាផ្នែកមួយនៃគម្រោងស្រាវជ្រាវរយៈពេល ២ឆ្នាំថ្នាក់តំបន់របស់វិទ្យាស្ថាន CDRI ស្តីពី "ការទូតស្តីពីទឹកមេគង្គ៖ ឆ្ពោះទៅអាងរួមគ្នាដើម្បីវឌ្ឍនភាព" ផ្តល់មូលនិធិដោយមូលនិធិពិសេសនៃសហប្រតិបត្តិការមេគង្គ-ឡានឆាង (MLC) តាមរយៈក្រសួង កិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (MoFAIC) កម្ពុជា។

## ឯកសារយោង


Abbashi, Shakeel Abbasia, Muhammad Zubair Anwara, Nusrat Habiba, Qaisar Khana and Kanwal Waqar. 2019. "Identifying Gender Vulnerabilities in Context of Climate Change in Indus Basin." *Environmental Development* 31: 34–42.

ADB (Asian Development Bank). 2013. *Asian Water Development Outlook 2013: Measuring Water Security in Asia and the Pacific*. Mandaluyong City: ADB.

Alam, Undala Z. 2002. "Questioning the Water Wars Rationale: A Case Study of the Indus Waters Treaty." *Geographical Journal* 168 (4): 341–353. doi.org/10.1111/j.0016-7398.200 2.00060.x.

Balraj K. Sidhu. (2013). The Kishenganga Arbitration – Transboundary Water Resources Governance –. *Enviromental Policy and Law*, *43/3*, 150. https://doi.org/10.3233/DEV-2012-12111

Biba, Sebastian. 2018. "China's 'Old' and 'New' Mekong River Politics: The Lancang-Mekong Cooperation from a Comparative Benefit-Sharing Perspective." *Water International* 43 (5): 622–641. doi.org/10.1080/00472336.2012.712257.

Campbell, Ian C. 2011. "Managing International River Basins: Successes and Failures of the Mekong River Commission." In *Water Resources Planning and Management*, edited by R. Quentin Grafton and Karren Hussey, 724–740. doi.org/10.1017/CBO9780511974304.037.

Chang, F. K. 2013. "The Lower Mekong Initiative and U.S. Foreign Policy in Southeast Asia: Energy, Environment and Power." *Orbis* 57 (2): 282–299. doi.org/10.1016/j.orbis.2013.02. 005.

Gerlak, Andrea K., and Andrea Haefner. 2017. "Riparianization of the Mekong River Commission." *Water International* 42 (7): 893–902. doi. org/10.1080/02508060.2017.1376 267.

Gholizadeh, Bahareh, and Mehrdad Niknami. 2020. "The Causes and Effects of Water Conflict: Evidence from Damava." *Bulgarian Journal of Agricultural Science* 26 (3): 598–604.

Haq, Inamul, and Sheeraz Ahmad Sofi. 2019. "Kashmir Conflict and Indus Water Treaty: An Analysis." *Kardan Journal of Social Sciences and Humanities* 2 (2): 44–56.

Hefny, Magdy. 2011. "Water Diplomacy: A Tool for Enhancing Water Peace and Sustainability in the Arab Region." Paper presented in preparation for the Second Arab Water Forum Theme 3: Sustainable and Fair Solutions for the Trans-Boundary Rivers and Groundwater Aquifers, Cairo, 20–23 Nov 2011.

Hirsch, P. (2016). The shifting regional geopolitics of Mekong dams. *Political Geography*, *51*, 63–74.

Khan, M. Yunus. 1990. "Boundary Water Conflict between India and Pakistan." *Water International* 15 (4): 195–199. doi.org/10.1080/02508069008691649.

Kittikhoun, Anoulak, and Denise Michèle Staubli. 2018. "Water Diplomacy and Conflict Management in the Mekong: From Rivalries to Cooperation." *Journal of Hydrology* 567: 654–667.

Li, Xinlin. 2012. "Hydropower in the Mekong River Basin: A Balancing Test." *Environmental Claims Journal* 24 (1): 51–69. doi.org/10.1080/10406026.2 012.663299.

Molen, Irna van der, and Antoinette Hildering. 2005. "Water: Cause for Conflict or Co-Operation?" *ISYP Journal on Science and World Affairs* 1 (2): 133–43.

Molnar, Kata, Rosa Cuppari, Susanne Schmeier and Siegfried Demuth. 2017. *Preventing Conflicts, Fostering Cooperation – The Many Roles of Water Diplomacy*. www.waterandchange.org/wp-content/ uploads/2018/02/PUB_Water-Diplomacy_Bericht.pdf,

MRC (Mekong River Commission). 2020. "MRC Secretariat Welcomes China's Pledge to Share Mekong Data but Suggests Harnessing Existing Platform." Mekong River Commision. www. mrcmekong.org/news-and-events/news/pr-mrcs-welcomes-china-pledge/.

Parashar, Sachin. 2020. "India Wants Pakistan to Prosecute David Headley for 26/11 Mumbai Terror." *Economic Times,* 20 Sep 2020. https://economictimes. indiatimes.com/news/defenc e/india-wants-pakistan-to-prosecute-david-headley-for-26/11-mumbai-terror-attacks/article show/788862 28.cms.

Petersen-Perlman, Jacob D., Jennifer C. Veilleux and Aaron T. Wolf. 2017. "International Water Conflict and Cooperation: Challenges and Opportunities." *Water International* 42 (2): 105–120.

Qureshi, Waseem Ahmad. 2017a. "The Indus Basin: Water Cooperation, International Law and the Indus Waters Treaty." *Michigan State International Law Review* 26 (1): 45–81.

Qureshi, Waseem Ahmad. 2017b. "The Indus Waters Treaty and the Role of World Bank as Mediator." *Willamette Journal of International Law and Dispute Resolution* 24 (2): 211–232.

Ranjan, Amit. 2016. "Disputed Waters: India, Pakistan and the Transboundary Rivers." *Studies in Indian Politics* 4 (2): 191–205.

Rao, Sahana. 2017. "Governance of Water Resources Shared by India and Pakistan under the Indus Waters Treaty: Successful Elements and Room for Improvement." *NYU Environmental Law Journal* 25: 108–139.

Sarfraz, Hamid. 2013. "Revisiting the 1960 Indus Waters Treaty." *Water International* 38 (2): 204–216.

Schmeier, Susanne. 2011. *Resilience to Climate Change-Induced Challenges in the Mekong River Basin The Role of the MRC.* Water Papers. www.worldbank. org/en/topic/water.

Sinha, Uttam Kumar, Arvind Gupta and Ashok Behuria. 2012. "Will the Indus Water Treaty Survive?" *Strategic Analysis* 36 (5): 735–752.

Sok, Serey. 2020. Transparent Data Sharing among Member Countries: Crucial to Sustainable Management of Mekong River System. *Mekong Connect*, *2*(1), 5–9.

Sunchindah, Apichai. 2005. "Water Diplomacy in the Lancang-Mekong-River Basin: Prospect and Challenges." Prepared for the Workshop on the Growing Integration of Greater Mekong Sub-regional ASEAN States in Asian Region, Yangon, Myanmar, 20–21 Sep 2005.

United Nations. 2002. "World's Water Problems Can Be 'Catalyst for Cooperation' Says Secretary-General in Message on World Water Day." Press Release, 26 Feb 2002. www.un.org/press/en/2002/sgsm8139.doc. htm.

Wani, Khursheed Ahmad, and P. Moorthy. 2014. "Indus Waters Treaty : An Emerging Flashpoint between India and Pakistan." *Pakistan Horizon* 67 (2): 41–59.

World Economic Forum. 2020. The Global Risks Report 2020. WEF_Global_Risk_Report_2020.pdf (weforum.org).

Zawahri, Neda A. 2008. "Designing River Commissions to Implement Treaties and Manage Water Disputes: The Story of the Joint Water Committee and Permanent Indus Commission." *Water International* 33 (4): 464–474.